ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ

## ស្តីពី

# សាលារៀនជំនាន់ថ្មី

ខែកញ្ញា ឆ្នាំ២០១៦

# បុព្វកថា

ការអប់រំប្រកបដោយគុណភាពជាកត្តាសំខាន់បំផុត។ ប្រទេសនីមួយៗជានិច្ចកាលត្រូវការធនធានមនុស្សដែលមានចំណេះដឹង និងជំនាញប្រកបដោយសមត្ថភាពខ្ពស់ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក៏ដូចជាកសាងសង្គមជាតិឱ្យបានរឹងមាំ។

ដើម្បីឆ្លើយតបនឹងទស្សនៈខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយស្ដីពីសាលារៀនជំនាន់ថ្មី ក្នុងគោលបំណងពង្រឹងគុណភាពនៅក្នុងប្រព័ន្ធអប់រំទាំងមូល។ ក្រសួងបានដាក់ឱ្យអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី ដែលជាលំនាំបន្តពីកម្មវិធីសាលាកុមារមេត្រី ប៉ុន្តែមានកម្រិតអនុវត្តប្រកបដោយស្តង់ដាគុណភាពខ្ពស់។

គោលនយោបាយសាលារៀនជំនាន់ថ្មីនឹងផ្តល់សេចក្តីណែនាំលម្អិត សម្រាប់បុគ្គលិកអប់រំ សិស្សានុសិស្សឱ្យយល់ដឹងកាន់តែច្បាស់អំពីគោលវិធីរៀន និងបង្រៀនថ្មីៗ រាប់ទាំងវិធីរៀនផ្អែកលើការស្គាល់បញ្ហា វិធីដោះស្រាយ និងវិធីរៀនបែបស្ថាបនា។ល។ ម្យ៉ាងវិញទៀតតាមរយៈវិធីរៀនថ្មីៗទាំងនេះ សាលារៀនជំនាន់ថ្មីនឹងនាំមកនូវនវានុវត្តអប់រំយ៉ាងទូលំទូលាយក្នុងប្រព័ន្ធសាលារៀនទាំងមូល។ សកម្មភាពមួយចំនួនទៀតរួមមានការងារគម្រោង ក្លិបអ្នកសិក្សាតាមមុខវិជ្ជា និងបច្ចេកវិទ្យាក្នុងការអប់រំនឹងរួមចំណែកលើកកម្ពស់នវានុវត្តអប់រំឲ្យកាន់តែច្រើនឡើងថែមទៀត។

គោលដៅសេចក្តីណែនាំនេះផ្តល់លទ្ធភាពឱ្យក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍធ្វើការវិនិយោគនៅតាមបណ្តាសាលារៀន ដែលបានជ្រើសរើសដើម្បីសម្រេចស្តង់ដាសិក្សាអតិបរមាសម្រាប់សិស្សានុសិស្ស និងយុវជនកម្ពុជា។ គំនិតផ្តួចផ្តើមសាលារៀនជំនាន់ថ្មីនឹងជួយដល់ប្រព័ន្ធអប់រំនៅកម្ពុជាឱ្យមានលទ្ធភាពប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពជាមួយប្រព័ន្ធអប់រំបណ្តាប្រទេសក្នុងសហគមន៍អាស៊ាន ដែលកំពុងតែទាមទារជាបន្ទាន់នូវកម្លាំងពលកម្មប្រកបដោយជំនាញសតវត្សរ៍ទី២១។ តម្រូវការនេះទាមទារឲ្យធនធានមនុស្សមានជំនាញខ្ពស់លើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។

ក្រសួងអប់រំ យុវជន និងកីឡាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមជួយឱ្យសម្រេចបានគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី។ គោលនយោបាយនេះជាមាគ៌ាដ៏ល្អក្នុងការជួយអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណតម្លៃ ជំនាញ និងសមត្ថភាពខ្ពស់។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថាស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សហគមន៍ជាតិ និងអន្តរជាតិនឹងចូលរួមគាំទ្រការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មីឱ្យទទួលបានជោគជ័យ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ខែកញ្ញា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**មាតិកា**


**១. សេចក្តីផ្តើម**………………………………………………………… ១

**២. ចក្ខុវិស័យ**………………………………………………………… ២

**៣. គោលបំណង**………………………………………………………… ២

**៤. គោលដៅ**………………………………………………………… ២

**៥. យុទ្ធសាស្ត្រ**………………………………………………………… ២

៥.១.ការជ្រើសរើសសាលារៀនយ៉ាងហ្មត់ចត់ ២

៥.២.ភាពជាដៃគូ ៣

៥.៣.ការទទួលខុសត្រូវរបស់សាលារៀនជំនាន់ថ្មី ៣

៥.៤.ការត្រួតពិនិត្យសាលារៀនជំនាន់ថ្មីដោយផ្ទាល់ពីថ្នាក់ជាតិ ៣

៥ .៥.ប្រាក់លើកទឹកចិត្តគ្រូបង្រៀន ៣

៥.៦.ដំណើរការស្វ័យភាពផ្សារភ្ជាប់នឹងការច្នៃប្រឌិតថ្មី ៣

៥.៧. ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានទូលំទូលាយដើម្បីជំរុញការច្នៃប្រឌិតថ្មី ៤

៥.៨.ការពង្រឹងសិទ្ធិអំណាចយុវជន ៤

៥ .៩.ការបង្កើនម៉ោងបង្រៀន និងរៀន ៤

៥.១០.ការដាក់ឱ្យអនុវត្តប្រភេទមុខវិជ្ជា ៤

៥.១១. មូលនិធិសមធម៌សង្គម ៤

៥.១២. គំរូសាលាក្នុងសាលា ៤

៥ .១៣.ការកាត់បន្ថយផលធៀបគ្រូ-សិស្ស ៤

៥ .១៤.ការផ្លាស់ប្តូរផ្នត់គំនិតបុគ្គល ៥

៥ .១៥.ការធ្វើទំនើបកម្មបរិស្ថានសិក្សា ៥

**៦. ផែនការសកម្មភាព**………………………………………………………… ៥

៦.១. ការបង្កើតយន្តការ ………………………………………………………… ៥

៦.២. ស្តង់ដាគតិយុត្ត………………………………………………………… ៥

៦.៣. ការគាំទ្រហិរញ្ញវត្ថុ ………………………………………………………… ៦

៦.៤ .ការបណ្តុះបណ្តាលធនធានមនុស្ស………………………………………… ៦

៦.៥. ដំណើរការអនុវត្តគម្រោង ………………………………………………… ៦

**៧. ការត្រួតពិនិត្យ និងការវាយតម្លៃ**………………………………………………… ៧

**៨. សេចក្តីសន្និដ្ឋាន**………………………………………………………… ៧

# ១. សេចក្តីផ្តើម

គោលនយោបាយនេះបានរៀបចំឡើង ដើម្បីផ្តល់ការណែនាំដល់មន្ត្រីគ្រប់គ្រងរដ្ឋបាលអប់រំ និងគ្រូបង្រៀនគ្រប់កម្រិតទាំងអស់ស្តីពីការអនុវត្ត**សាលារៀនជំនាន់ថ្មី**ទូទាំងព្រះរាជាណាចក្រកម្ពុជា។ ការបង្កើតសាលារៀនជំនាន់ថ្មីគឺជាគោលនយោបាយផ្លូវការមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា អនុលោមតាមក្របខ័ណ្ឌកំណែទម្រង់វិស័យអប់រំ ដែលបានប្រកាសឱ្យប្រើដោយក្រសួងក្នុងឆ្នាំ២០១៣ នៅក្នុងក្របខ័ណ្ឌកំណែទម្រង់វិស័យអប់រំ "សាលារៀនជំនាន់ថ្មីស្ថិតនៅក្នុង**ចំណុចទី១៥**"។ គោលនយោបាយនេះត្រូវបានរៀបចំឡើង ស្របនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខណៈដែលព្រះរាជាណាចក្រកម្ពុជាបានឈានចូលក្នុងសតវត្សរ៍ទី២១ ប្រព័ន្ធអប់រំនៅមានបញ្ហាប្រឈមជាច្រើន។ បញ្ហាប្រឈមទាំងនេះលេចចេញពីប្រភពជាច្រើនរួមមានសមាហរណកម្មនៃសហគមន៍អាស៊ាន ការកើនឡើងនៃការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច ការជ្រៀតចូលយ៉ាងឆាប់រហ័សនូវប្រព័ន្ធបច្ចេកវិទ្យានៅក្នុងសង្គមកម្ពុជា ការកើនឡើងផ្នែកនគរូបនីយកម្ម ការពង្រីកសាលារៀនឯកជន និងចំនួនពលរដ្ឋជាយុវជនដ៏ច្រើនសន្ធឹកសន្ធាប់ ដែលតម្រូវឱ្យមានសេចក្តីណែនាំទូលំទូលាយអំពីជម្រើស និងគំនិតប្រកួតប្រជែងនៅក្នុងពិភពលោកបច្ចុប្បន្ន។ សាលារៀនជំនាន់ថ្មីនឹងជួយព្រះរាជាណាចក្រកម្ពុជាដោះស្រាយបញ្ហាប្រឈមទាំងនេះ តាមរយៈការលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយនិរន្តរភាព។

ក្រសួងបានផ្តល់អាទិភាពខ្ពស់ លើការកែលម្អគុណភាពអប់រំទាំងនៅកម្រិតបឋមសិក្សានិងមធ្យមសិក្សា ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមខាងលើ។ អស់រយៈពេលជាច្រើនឆ្នាំ ក្រសួងទទួលបានជោគជ័យមួយចំនួនក្នុងផ្នែកនេះ ប៉ុន្តែនៅមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញបន្ថែម។ ព្រះរាជាណាចក្រកម្ពុជានៅមានធនធានតិចតួច។ ការបែងចែកធនធានទាំងនេះឱ្យទៅដល់គ្រប់សាលារៀនទូទាំងប្រទេសបានធ្វើឱ្យគោលដៅលើកកម្ពស់គុណភាពអប់រំនៅមានកម្រិត។ ជម្រើសគំរូអភិវឌ្ឍន៍ទីពីរដែលនឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលដោះស្រាយតម្រូវការមូលដ្ឋានរបស់សាលារៀនទាំងអស់ នោះគឺការអនុញ្ញាតឱ្យមានការវិនិយោគកម្រិតខ្ពស់ ដើម្បីទទួលបានស្តង់ដានៃការអប់រំអតិបរមា។ សាលារៀនជំនាន់ថ្មីបង្កើតឡើងដើម្បីបំពេញតម្រូវការខាងលើនេះ។ ការបង្កើតសាលារៀនជំនាន់ថ្មីគឺជាលំនាំបន្តពីកិច្ចខិតខំប្រឹងប្រែងនៃកម្មវិធីសាលាកុមារមេត្រី ដោយយកលំនាំតាមការអនុវត្តនៅក្នុងបណ្តាប្រទេសមួយចំនួនដែលសាលារៀនសាធារណៈមួយចំនួនទទួលបានស្វ័យភាពយ៉ាងច្រើនពីរដ្ឋាភិបាល ដើម្បីជំរុញនវានុវត្តអប់រំ។ ចំណុចនេះសំដៅជាពិសេសដល់ចលនាសាលារៀនធម្មនុញ្ញ (Charter School Movement)។ សាលារៀនបែបនេះបានជួយស្តារវិធានការនានាដែលធានាបាន អភិបាលកិច្ចល្អ និងជួយពង្រឹងភាពល្បីល្បាញរបស់សាលារៀនសាធារណៈលើផ្នែកមួយចំនួនដែលសាលាខិតខំប្រឹងប្រែងធ្វើឱ្យសម្រេចបាន។ ក្រសួងអប់រំ យុវជន និងកីឡា បានសិក្សាបទពិសោធនេះយ៉ាងប្រុងប្រយ័ត្នបំផុត និងបានកែតម្រូវស្របតាមបរិបទប្រទេសកម្ពុជា។ ក្រសួងសង្ឃឹមថា បទពិសោធនេះនឹងទទួលបានជោគជ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.ចក្ខុវិស័យ

សាលារៀនជំនាន់ថ្មីនឹងនាំមកនូវក្របខណ្ឌរដ្ឋបាលថ្មីដែលអាចធានាលក្ខខណ្ឌចាំបាច់ជាសារវន្ត និងមានប្រសិទ្ធភាពក្នុងការធ្វើវិនិយោគប្រព័ន្ធអប់រំដោយជោគជ័យ។

## ៣.គោលបំណង

សាលារៀនជំនាន់ថ្មីព្យាយាមបង្កើតគំរូអភិវឌ្ឍន៍ថ្មីនៅក្នុងប្រព័ន្ធអប់រំសាធារណៈ ដែលនឹងនាំទៅដល់ការបង្កើតសាលារៀនសាធារណៈស្វយ័ត ដែលទទួលបានការវិនិយោគខ្ពស់ផ្សារភ្ជាប់នឹងស្តង់ដាថ្មីមានគណនេយ្យភាព និងអភិបាលកិច្ចល្អ ព្រមទាំងស្តង់ដាវិជ្ជាជីវៈសម្រាប់ការសិក្សានៅក្នុងសតវត្សរ៍ទី២១។

## ៤.គោលដៅ

៤.១. បង្កើតសាលារៀនសាធារណៈស្វយ័តគ្រប់គ្រងដោយវិន័យតឹងរឹងក្នុងការបំពេញភារកិច្ច និងមានគណនេយ្យភាពផ្សារភ្ជាប់ទៅនឹងការវិនិយោគខ្ពស់។

៤.២. បង្កើតក្រុមប្រឹក្សាភិបាលដែលនឹងធ្វើឱ្យសាលាទទួលខុសត្រូវសម្រាប់ការបំពេញភារកិច្ច។

៤.៣. បង្កើតប្រព័ន្ធទទួលស្គាល់ដែលនឹងសម្របសម្រួលដល់ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលដោយប្រកាន់ភ្ជាប់ទៅនឹងគោលការណ៍ស្នូលរបស់សាលារៀនជំនាន់ថ្មី។

៤.៤. ផ្តល់សេរីភាពស្ថាប័នថ្មី (ឧ.ស្វ័យភាពប្រតិបត្តិការ) ដើម្បីធ្វើឱ្យមានការច្នៃប្រឌិតក្នុងវិធីរៀបចំបង្កើត និងផ្តល់សេវាអប់រំ។

៤.៥. ធ្វើឱ្យប្រព័ន្ធអប់រំមានប្រសិទ្ធភាព និងសមធម៌សង្គមក្នុងដំណើរការបង្រៀន និងរៀនដោយមានប្រព័ន្ធបែងចែកធនធានឱ្យសមស្របសំដៅលើកកម្ពស់សេវាអប់រំ។

៤.៦. កែលម្អស្តង់ដាបង្រៀនតាមរយៈវិធីសាស្ត្រថ្មីៗដែលរួមបញ្ចូល ការជ្រើសរើសគ្រូដោយការប្រកួតប្រជែង ប្រាក់លើកទឹកចិត្តអាស្រ័យលើភារកិច្ច ការបំប៉នសមត្ថភាពគ្រូបង្រៀនបន្ថែមលើផ្នែកបច្ចេកវិទ្យាអប់រំ វិធីសាស្ត្រ STEM និងការសិក្សាឱ្យស្គាល់បញ្ហា និងការរកដំណោះស្រាយ ព្រមទាំងគន្លងអាជីពគ្រូបង្រៀនជាក់លាក់ភ្ជាប់ទៅនឹងឱកាសអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន (ឧ. អាហារូបករណ៍គ្រូដើម្បីបន្តការសិក្សាពេលអនាគត)។

៤.៧. ពង្រីកសេវាអប់រំសម្រាប់យុវជនកម្ពុជាដែលនឹងរួមបញ្ចូលទាំងសេវាប្រឹក្សាអាជីព សកម្មភាពសិក្សាប្លែកៗ ដូចជា៖ ការងារគម្រោង ក្លិបអ្នកសិក្សាតាមមុខវិជ្ជា ការសិក្សាតាមឧបករណ៍ចល័ត និងកម្មវិធីសិក្សាបំណិនជីវិត។

## ៥. យុទ្ធសាស្ត្រ

ដើម្បីសម្រេចបានគោលបំណង និងគោលដៅខាងលើ យុទ្ធសាស្ត្រសំខាន់ៗមានដូចខាងក្រោម៖

**៥.១.ការជ្រើសរើសសាលាយ៉ាងហ្មត់ចត់**

- ជ្រើសរើសសាលារៀនគោលដៅយ៉ាងហ្មត់ចត់
- ជ្រើសរើសយកសាលារៀនដែលមានសក្តានុពលពេញលេញក្នុងការប្រើប្រាស់ការវិនិយោគឱ្យមានប្រសិទ្ធភាពខ្ពស់។

### ៥.២.ភាពជាដៃគូ

កសាងភាពជាដៃគូជិតស្និទ្ធជាមួយតួអង្គមិនមែនរដ្ឋ និងវិស័យឯកជន ដើម្បីជួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការអនុវត្ត និងផ្គត់ផ្គង់ធនធានដល់សាលារៀនជំនាន់ថ្មី។

### ៥.៣.ការទទួលខុសត្រូវរបស់សាលារៀនជំនាន់ថ្មី

ពង្រឹងការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងសាលាដោយប្រើប្រាស់ពហុយុទ្ធសាស្ត្ររួមមានៈ

- ជ្រើសរើសគណៈគ្រប់គ្រងសាលាតាមរយៈការប្រកួតប្រជែង ការលើកទឹកចិត្តផ្សារភ្ជាប់នឹងការបំពេញភារកិច្ចបានល្អ
- បង្កើតក្រុមប្រឹក្សាភិបាលថ្នាក់ជាតិថ្មីមួយដែលពង្រឹងការអនុវត្តលក្ខណៈវិនិច្ឆ័យតឹងរឹងសម្រាប់ការរៀបចំសាលារៀនជំនាន់ថ្មី
- ដកហូតការទទួលស្គាល់ឋានៈជាសាលារៀនជំនាន់ថ្មី និងដកការវិនិយោគមកវិញក្នុងករណីដែលសាលាមិនបានបំពេញលក្ខណៈវិនិច្ឆ័យដូចបានព្រមព្រៀង។

### ៥.៤.ការត្រួតពិនិត្យសាលារៀនជំនាន់ថ្មីដោយផ្ទាល់ពីថ្នាក់ជាតិ

- ត្រួតពិនិត្យដោយផ្ទាល់ពីថ្នាក់ជាតិទៅលើសាលារៀនសាធារណៈស្វយ័ត ដែលបានរៀបចំជាសាលារៀនជំនាន់ថ្មី តាមរយៈក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ បង្កើតឡើងដោយក្រសួងអប់រំ យុវជន និងកីឡា (ដូចមានចែងក្នុងចំណុច ៥.៣ ខាងលើ)
- ប្រគល់អំណាចគ្រប់គ្រងទៅឱ្យក្រុមប្រឹក្សាភិបាលថ្នាក់មូលដ្ឋាន នៅពេលដែលចំនួនសាលារៀនជំនាន់ថ្មីកើនឡើងនៅឆ្នាំបន្តបន្ទាប់។

### ៥.៥. ប្រាក់លើកទឹកចិត្តគ្រូ

ផ្ដល់ប្រាក់លើកទឹកចិត្តពិសេសដល់គ្រូបង្រៀន ដើម្បីលើកកម្ពស់ការបំពេញភារកិច្ចឈានទៅលុបបំបាត់ការបង្រៀនឯកជនសិស្សរបស់ខ្លួនដែលប៉ះពាល់ដល់វិជ្ជាជីវៈ និងសេចក្តីថ្លៃថ្នូរគ្រូបង្រៀន។

### ៥.៦.ដំណើរការស្វ័យភាពផ្សារភ្ជាប់នឹងការច្នៃប្រឌិតថ្មី

- អនុញ្ញាតឱ្យប្រតិបត្តិការក្រៅក្របខណ្ឌគោលនយោបាយដែលបានអនុវត្តនៅក្នុងសាលារៀនធម្មតា ដរាបណាសាលានោះអាចបង្ហាញឱ្យឃើញសកម្មភាពដែលបានស្នើសុំលើកកម្ពស់ការច្នៃប្រឌិតថ្មីដើម្បីបង្កើនគុណភាពអប់រំ មានសិទ្ធិជ្រើសរើសគ្រូមកពីសាលានានា
- កែលម្អកម្មវិធីសិក្សា ការប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្កើនប្រសិទ្ធភាពអប់រំ ដូចជាការធ្វើកិច្ចតែងការបង្រៀនអេឡិចត្រូនិក ការសិក្សាតាមឧបករណ៍ចល័ត ជាដើម។ល។ និងទម្រង់ផ្សេងៗទៀតនៃការច្នៃប្រឌិតថ្មីក្នុងការសិក្សា ព្រមទាំងការផ្ដល់ឱ្យដំណើរការស្វ័យភាពនិងផ្អែកលើភស្តុតាងនៃការច្នៃប្រឌិតថ្មីៗ។

## ៥.៧.ការប្រើប្រាស់បច្ចេកវិទ្យាឱ្យបានទូលំទូលាយដើម្បីជំរុញការច្នៃប្រឌិតថ្មី

ប្រើប្រាស់បច្ចេកវិទ្យាដែលនឹងក្លាយជាធាតុគន្លឹះនៅក្នុងសាលារៀនជំនាន់ថ្មី ដោយមិនគ្រាន់តែរាប់បញ្ចូលការទទួលបានការប្រើប្រាស់ឧបករណ៍រឹងប៉ុណ្ណោះទេ ប៉ុន្តែសិស្សត្រូវចេះប្រើកម្មវិធីទន់ ក្នុងការអប់រំទំនើបទៀតផង ដែលនឹងជួយពង្រឹងការសិក្សា ការបង្រៀន និងការវាយតម្លៃ (ឧទាហរណ៍ កម្មវិធី literatu, 3D Classroom ។ល។)

## ៥.៨.ការពង្រឹងសិទ្ធិអំណាចយុវជន

ទម្លាប់សិស្សឱ្យអនុវត្តតួនាទីដ៏សំខាន់លើការគ្រប់គ្រងសម្ភារៈ និងសេវាថ្មីៗរៀបចំឱ្យមានមណ្ឌលយុវជននៅក្នុងសាលា ដែលផ្តល់កន្លែងឱ្យសិស្សធ្វើផែនការសកម្មភាពពិសេស ដោយប្រើប្រាស់មូលនិធិវិនិយោគពិសេស ដែលសាលារៀនផ្តល់ឱ្យ ព្រមទាំងទទួលបានសេវាប្រឹក្សាអាជីព និងប្រឹក្សាយោបល់ផ្សេងៗ។

## ៥.៩. ការបង្កើនម៉ោងបង្រៀន និងរៀន

- បង្កើនម៉ោងបង្រៀនដល់ ៣៤ ម៉ោងសិក្សាក្នុងមួយសប្តាហ៍នៅកម្រិតបឋមសិក្សា និង៤០ ម៉ោងសិក្សាក្នុងមួយសប្តាហ៍ សម្រាប់មធ្យមសិក្សា
- តម្រូវឱ្យគ្រូប្រកាន់ខ្ជាប់វិន័យតាមសេចក្តីណែនាំផ្លូវការដែលតម្រូវឱ្យគាត់បង្រៀនពេញម៉ោង (១៨ម៉ោងក្នុងមួយសប្តាហ៍សម្រាប់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ និង១៦ម៉ោងក្នុងមួយសប្តាហ៍សម្រាប់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ)។

## ៥.១០.ការដាក់ឱ្យអនុវត្តប្រភេទមុខវិជ្ជា

តម្រូវឱ្យប្រើប្រាស់ម៉ោងបង្រៀនបន្ថែមដើម្បីផ្តល់ការអនុវត្តប្រភេទមុខវិជ្ជាពិសេសដែលអាចផ្តោតលើមុខវិជ្ជា STEM ភាសាបរទេស ឬផ្នែកផ្សេងទៀតតាមតម្រូវការរបស់សហគមន៍ក្នុងមូលដ្ឋាន។

## ៥.១១.មូលនិធិសមធម៌សង្គម

- តម្រូវឱ្យបង្ហាញការឆ្លើយតបនឹងតម្រូវការសមាជិកសហគមន៍ក្រីក្រ ផ្តល់ការលើកទឹកចិត្តដល់គ្រួសារក្រីក្រក្នុងការរក្សាកូនឱ្យមកទទួលការអប់រំ
- បង្កើតមូលនិធិសមធមិសង្គម ដែលនឹងអាចឱ្យសាលាទទួលបានមូលនិធិបន្ថែមដើម្បីជួយដល់សិស្សក្រីក្រ
- លុបបំបាត់ចោលឱ្យបានដាច់ខាតការយកតម្លៃក្រៅផ្លូវការដែលប៉ះពាល់ដល់សិស្សក្រីក្រ។

## ៥.១២.គំរូសាលាក្នុងសាលា

- ជ្រើសរើសយុទ្ធសាស្ត្រ "សាលាក្នុងសាលា" ដែលក្នុងនោះមានការបង្កើតរចនាសម្ព័ន្ធថ្មីមួយនៅក្នុងសាលាដែលមានស្រាប់ដើម្បីដោះស្រាយបញ្ហាប្រឈម
- តម្រូវឱ្យមានការជ្រើសរើសនាយកសាលានិងគ្រូបង្រៀនតាមរយៈការប្រកួតប្រជែងការជ្រើសរើសសិស្ស (ឧ. ការប្រឡងចូល) ការបង្កើតកម្មវិធីសិក្សាថ្មីហើយនិងការរិះរកវិធានការផ្សេងៗ

ដទៃទៀត ដោយផ្សារភ្ជាប់ជាមួយគំរូសាលារៀនជំនាន់ថ្មី។

### ៥.១៣. ការកាត់បន្ថយផលធៀបគ្រូ-សិស្ស

អនុញ្ញាតឱ្យសាលារៀនកាត់បន្ថយផលធៀបគ្រូសិស្ស ដើម្បីបង្កើនគុណភាពការសិក្សាជាបុគ្គល។

### ៥.១៤. ការផ្លាស់ប្តូរផ្នត់គំនិតបុគ្គល

ផ្លាស់ប្តូរឥរិយាបទគ្រប់អ្នកពាក់ព័ន្ធរួមមាន នាយក នាយិកាសាលា គ្រូបង្រៀន មន្ត្រីរដ្ឋបាល សិស្ស មាតាបិតា ដើម្បីឆ្លើយតបទៅនឹងការសិក្សាក្នុងសតវត្សរ៍ទី២១។

### ៥.១៥. ការធ្វើទំនើបកម្មបរិស្ថានសិក្សា

ប្រើគំនិតច្នៃប្រឌិតថ្មីក្នុងស្ថាបត្យកម្មអប់រំ ដើម្បីកែប្រែបន្ទប់រៀន និងបន្ទប់ផ្សេងៗទៀតក្នុងសាលារៀនឱ្យសមស្របទៅនឹងស្តង់ដាសាលារៀនសតវត្សរ៍ទី២១។

## ៦.ផែនការសកម្មភាព

ដើម្បីសម្រេចយុទ្ធសាស្ត្រខាងលើ ត្រូវយកចិត្តទុកដាក់លើសកម្មភាពមួយចំនួនដូចខាងក្រោមៈ

### ៦.១. ការបង្កើតយន្តការ

- បង្កើតក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់សម្របសម្រួលសាលារៀនជំនាន់ថ្មី។
- បង្កើតអនុគណៈកម្មការសម្រាប់វាយតម្លៃ និងទទួលស្គាល់សាលារៀនជំនាន់ថ្មី ដោយផ្តល់យោបល់ទៅដល់ក្រុមប្រឹក្សាភិបាល។

### ៦.២. ការបង្កើតក្របខណ្ឌស្តង់ដា គតិយុត្ត

- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជាប្រធានក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ
- សមាជិកក្រុមប្រឹក្សាភិបាលត្រូវរួមបញ្ចូលតំណាងមកពីនាយកដ្ឋានពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងតំណាងមកពីវិស័យឯកជន
- ក្រុមប្រឹក្សាភិបាលថ្នាក់ក្រោមជាតិដឹកនាំដោយប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ហើយសមាជិកត្រូវរួមបញ្ចូលតំណាងមកពីការិយាល័យពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងតំណាងមកពីវិស័យឯកជន
- ក្រុមប្រឹក្សាភិបាលថ្នាក់ក្រោមជាតិនឹងមានតួនាទីកាន់តែសកម្មនៅពេលសាលារៀនជំនាន់ថ្មីបានអនុវត្តកាន់តែមានចំនួនច្រើន ហើយពេលនោះក្រុមប្រឹក្សាភិបាលថ្នាក់ជាតិត្រូវផ្ទេរអំណាចទទួលខុសត្រូវទៅឱ្យក្រុមប្រឹក្សាភិបាលថ្នាក់ក្រោមជាតិវិញ
- សាលារៀនជំនាន់ថ្មីនឹងធ្វើរបាយការណ៍ដោយផ្ទាល់ជូនក្រុមប្រឹក្សាភិបាល ដែលប្រការនេះផ្តល់ឱ្យសាលាទទួលបានស្វ័យភាពខ្ពស់ និងសេរីភាពក្នុងដំណើរការប្រតិបត្តិ

- របនាសម្ព័ន្ធប្រតិបត្តិសាលារៀនជំនាន់ថ្មីនឹងត្រូវអនុវត្តតាមសេចក្តីណែនាំលម្អិតដូចមានបង្ហាញក្នុងគោលការណ៍ប្រតិបត្តិរបស់សាលារៀនជំនាន់ថ្មី។

## ៦.៣. ការគាំទ្រហិរញ្ញវត្ថុ

- សាលារៀនជំនាន់ថ្មីអាចទទួលបានធនធានហិរញ្ញវត្ថុពីប្រភពនានារួមទាំងការផ្តល់ហិរញ្ញវត្ថុដោយផ្ទាល់ពីរាជរដ្ឋាភិបាល ស្ថាប័នពហុភាគី និងទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាលព្រមទាំងមូលនិធិឯកជនជាដើម
- សាលារៀនជំនាន់ថ្មីអាចចរចាស្នើសុំថវិកាបដិភាគពីមាតាបិតាសិស្សដោយស្ម័គ្រចិត្តបន្ទាប់ពីអនុវត្តបាន៣ឆ្នាំ តែត្រូវភ្ជាប់ជាមួយលក្ខខណ្ឌដែលសាលារក្សាបាននូវការទទួលស្គាល់
- ក្រសួងនឹងរៀបចំបង្កើតមូលនិធិសមធម៌សង្គម ដើម្បីធានាថាការចរចាជាមួយមាតាបិតាសិស្សឱ្យចូលរួមបដិភាគថវិកា ដោយមិនឱ្យមានផលប៉ះពាល់អវិជ្ជមានដល់គ្រួសារសិស្សក្រីក្រឡើយ
- សាលារៀនជំនាន់ថ្មីអាចស្វែងរកប្រាក់ចំណូលអង្គភាពតាមរយៈការជួលអាហារដ្ឋានសាលារៀន ការវិនិយោគប្រាក់អំណោយ និងទម្រង់ផ្សេងៗទៀតនៃសកម្មភាពរកប្រាក់ចំណូលក្នុងមូលដ្ឋាន ដើម្បីធាននានិរន្តរភាព
- សាលារៀនជំនាន់ថ្មីនឹងរៀបចំផែនការវិនិយោគក្នុងឆ្នាំនីមួយៗ ដើម្បីជួសជុល និងកែលម្អដោយប្រើទម្រង់ស្តង់ដាដែលមានផ្តល់ជូនក្នុងគោលការណ៍ប្រតិបត្តិសម្រាប់សាលារៀនជំនាន់ថ្មី។

## ៦.៤. ការបណ្តុះបណ្តាលធនធានមនុស្ស

- ដើម្បីធានាការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មីឱ្យមានប្រសិទ្ធភាពខ្ពស់ ក្រសួងនឹងរៀបចំបណ្តុះបណ្តាលបុគ្គលិកសាលារៀនជំនាន់ថ្មីដោយប្រើប្រាស់ឯកសារបណ្តុះបណ្តាល ដែលមានស្រាប់ និងផ្តល់ជូនក្នុងឯកសារគោលការណ៍ប្រតិបត្តិសាលារៀនជំនាន់ថ្មី
- ឯកសារសម្រាប់បំប៉នទាំងនេះនឹងត្រូវអនុវត្ត តាមរយៈការផ្សារភ្ជាប់ជាមួយបុគ្គលិកជាតិគ្រូឧទ្ទេសមកពីស្ថាប័នខាងក្រៅ ដៃគូអភិវឌ្ឍនិងពីសង្គមស៊ីវិល។

## ៦.៥. ដំណើរការអនុវត្តគម្រោង

- ក្នុងឆ្នាំនីមួយៗ សាលារៀនជំនាន់ថ្មីត្រូវរៀបចំ ផែនការវិនិយោគ ដោយប្រើគំរូស្តង់ដា ដែលបង្កលក្ខណៈងាយស្រួលឱ្យសាលាសម្រេចបានសូចនាករ លក្ខណៈវិនិច្ឆ័យទទួលស្គាល់ និងនីតិវិធីដែលមានបង្ហាញក្នុងគោលការណ៍ប្រតិបត្តិសាលារៀនជំនាន់ថ្មី
- ក្រុមប្រឹក្សាភិបាលត្រូវធានាថា សាលារៀនជំនាន់ថ្មីមានគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនមានសមត្ថភាពខ្ពស់ ដែលត្រូវបានជ្រើសរើសតាមការប្រកួតប្រជែងសមត្ថភាព និងឆ្លងកាត់ការវាយតម្លៃរៀងរាល់ឆ្នាំដោយក្រុមប្រឹក្សាភិបាល ដើម្បីបន្តកិច្ចសន្យាជាមួយសាលារៀនជំនាន់ថ្មី
- ផែនការវិនិយោគដែលបានអនុម័តនឹងទទួលបានធនធាន ដោយប្រើលំហូរថវិកាដូចបានលម្អិតក្នុងចំណុច ៦.៣ ខាងលើ។

## ៧.ការត្រួតពិនិត្យ និងការវាយតម្លៃ

ក្របខណ្ឌនៃការអនុវត្តសាលារៀនជំនាន់ថ្មី ត្រូវអនុវត្តការត្រួតពិនិត្យ និងការវាយតម្លៃដោយប្រើយុទ្ធសាស្ត្រពីរ។ យុទ្ធសាស្ត្រទីមួយផ្តោតទៅលើសូចនាករ"ដំណើរការ"ដែលអាចជួយសាលារៀនជំនាន់ថ្មីឱ្យបន្តធ្វើការកែលម្អសេវាអប់រំលើផ្នែកជាច្រើនរួមទាំងបរិស្ថាននៃការបង្រៀន និងរៀន សេវាបណ្ណាល័យ សេវាប្រឹក្សាអាជីព បន្ទប់វិទ្យាសាស្ត្រ និងបន្ទប់បច្ចេកវិទ្យាព័ត៌មាន និងផ្នែកដទៃទៀត។ គោលបំណងនៃការវាយតម្លៃទៅលើសូចនាករ ដំណើរការគឺមានលក្ខណៈជាការវាយតម្លៃតាមដំណាក់ ហើយនឹងត្រូវអនុវត្តដោយប្រើឧបករណ៍ស្តង់ដា ដែលបង្ហាញក្នុងឯកសារគោលការណ៍ប្រតិបត្តិសាលារៀនជំនាន់ថ្មី។ យុទ្ធសាស្ត្រទីពីរសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃត្រូវតម្រូវតាមការវាយតម្លៃដែលបានព្រមព្រៀងជាមួយលក្ខណៈវិនិច្ឆ័យទទួលស្គាល់គុណភាពដែលមានចែងក្នុងសេចក្តីណែនាំគោលនយោបាយប្រតិបត្តិសម្រាប់សាលារៀនជំនាន់ថ្មី។ ការវាយតម្លៃដើម្បីទទួលស្គាល់ត្រូវធ្វើឡើងតែម្តងទេក្នុងមួយឆ្នាំនិងឈានទៅសម្រេចផ្តល់វិញ្ញាបនបត្រទទួលស្គាល់សាលារៀនជំនាន់ថ្មី។ វិញ្ញាបនបត្រនេះនឹងផ្តល់លទ្ធភាពឱ្យសាលារៀនជំនាន់ថ្មីទទួលបានប្រភពថវិកាពិសេស ដើម្បីឱ្យសាលារៀនអាចសម្រេចបានស្តង់ដាអប់រំខ្ពស់បំផុតតាមដែលអាចធ្វើបាន។ ផ្ទុយមកវិញ បើសាលារៀនបាត់បង់ការទទួលស្គាល់ឋានៈជាសាលារៀនជំនាន់ថ្មី សាលានឹងក្លាយជាសាលារៀនធម្មតាវិញ ហើយនឹងត្រូវបាត់បង់សិទ្ធិទទួលបានកញ្ចប់ថវិកាពិសេសនិងបុព្វសិទ្ធិដទៃទៀតដែលផ្តល់ជូនសម្រាប់សាលារៀនជំនាន់ថ្មី (ឧ.ស្វយ័តភាពប្រតិបត្តិ គោលដៅ ៩.៥)។

## ៨.សេចក្តីសន្និដ្ឋាន

គំរូកម្មវិធីសាលារៀនជំនាន់ថ្មីបង្កើតបាននូវលក្ខខណ្ឌដើម្បីទទួលបានជោគជ័យ សំដៅធានាការវិនិយោគលើវិស័យអប់រំប្រកបដោយប្រសិទ្ធភាពក្នុងសាលារៀនជាច្រើន។ ការដាក់ឱ្យអនុវត្តប្រព័ន្ធវាយតម្លៃទទួលស្គាល់សាលារៀនជំនាន់ថ្មី ដែលធានាស្តង់ដាខ្ពស់នៃអភិបាលកិច្ចល្អរួមមាន តម្លាភាព គណនេយ្យភាព និងការចូលរួម បង្កើតបានជាកម្លាំងទាក់ទាញការវិនិយោគថ្មីៗក្នុងវិស័យអប់រំ ដែលការគ្រប់គ្រងអប់រំបែបនេះ ពុំធ្លាប់មានទេក្នុងវិស័យអប់រំសាធារណៈ។ យើងរំពឹងថា ការខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបង្កើតសាលារៀនជំនាន់ថ្មី នឹងទាក់ទាញការវិនិយោគក្នុងកម្រិតខ្ពស់ជាងមុន ហើយការវិនិយោគទាំងនោះភាគច្រើននឹងទទួលបានពីវិស័យឯកជន។